**សមាគមថែរក្សាបរិស្ថាន និង វប្បធម៌ (សេប៉ា)**

*Culture and Environment Preservation Association (CEPA)*

# ជីវភាពរស់នៅ និងទិន្នន័យគ្រួសាររបស់ប្រជាជន ១៥ភូមិ

## តាមដងទន្លេសេសាន ខេត្តស្ទឹងត្រែង ឆ្នាំ២០០៧

# Livelihood and Family's Profile of People 15 Villages along SeSan River, Stung Treng



ខែ មិថុនា ឆ្នាំ ២០០៨

**ក្រុមការងារកែសម្រួល និងរៀបចំ**

| | | |
|---|---|---|
| លោក តឹក វណ្ណារ៉ា | មន្ត្រីគ្រប់គ្រងកម្មវិធី | អង្គការសេប៉ា |
| លោក វង្ស គង្គា | មន្ត្រីគម្រោងធនធានទឹក | អង្គការសេប៉ា |
| លោក ពាក្យ សារ៉ែន | មន្ត្រីជំនួយការគម្រោងធនធានទឹក | អង្គការសេប៉ា |
| លោក ហុង ឆាយ | បុគ្គលិកស្ម័គ្រចិត្ត | អង្គការសេប៉ា |
| ក. ធីម បុប្ផា | បុគ្គលិកគម្រោងធនធានទឹក | អង្គការសេប៉ា |
| ក. សុខ សុភក្តិ | បុគ្គលិកស្ម័គ្រចិត្តគម្រោងធនធានទឹក | អង្គការសេប៉ា |
| ក. ឡៅ ចន្ថា | បុគ្គលិកស្ម័គ្រចិត្តគម្រោងធនធានទឹក | អង្គការសេប៉ា |
| ក. អ៊ឹម សុផាណារី | បុគ្គលិកស្ម័គ្រចិត្ត | អង្គការសេប៉ា |
| ក. អ៊ិត ចាន់ធឿន | បុគ្គលិកស្ម័គ្រចិត្ត | អង្គការសេប៉ា |

| **គណៈកម្មការត្រួតពិនិត្យ** | **តួនាទី** | **ស្ថាប័ន** |
|---|---|---|
| លោក ទេព ប៊ុណ្ណារិទ្ធិ | នាយកប្រតិបត្តិ | អង្គការសេប៉ា |
| លោក ប៊ូ សារឿន | មន្ត្រីឯកទេសទំនាក់ទំនង | ធនាគារពិភពលោក |
| លោក តឹក វណ្ណារ៉ា | មន្ត្រីគ្រប់គ្រងកម្មវិធី | អង្គការសេប៉ា |
| លោក ហាក់ វិមាន | អនុប្រធានមន្ទីរបរិស្ថាន និងជានាយកតំបន់រ៉ាមសារ | មន្ទីរបរិស្ថានខេត្តស្ទឹងត្រែង |
| លោក ឆិន ឆាំ | អនុប្រធានការិយាល័យ | មន្ទីរធនធានទឹក និង ឧតុនិយមខេត្តស្ទឹងត្រែង |

**ខែ មិថុនា ឆ្នាំ ២០០៨**

# អារម្ភកថា

ពីមួយថ្ងៃទៅមួយថ្ងៃតែងមានការវិវឌ្ឍន៍ និង មានការប្រែប្រួលជាប្រចាំ ។ ការប្រែប្រួលមួយចំនួនឈានទៅរកការរីកចំរើន ប៉ុន្តែការប្រែប្រួលមួយចំនួនឈានទៅរកការវិចរិល និង ហិនហោច ។ កម្ពុជាដើម្បីអភិវឌ្ឍប្រទេស រដ្ឋាភិបាលបានខិតខំរៀបចំជាយុទ្ធសាស្ត្រ និង គោលនយោបាយជាច្រើន ដូចជាយុទ្ធសាស្ត្រត្រីកោណនៅអណត្តិទី៣ និង យុទ្ធសាស្ត្រចតុកោណនៅអណត្តិទី៤ សំដៅទៅរកកំណើនសេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រ ។ ប្រទេសកម្ពុជា មានខឿនសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្ម និង ធនធានធម្មជាតិ ។ នាពេលបច្ចុប្បន្ននេះ ធនធានធម្មជាតិត្រូវបានទាញយកមកអភិវឌ្ឍន៍តាមរយៈការផ្តល់ដីសម្បទាន ព្រៃសម្បទាន ទេសចរណ៍ធម្មជាតិ ការជីករករ៉ែក្រោមដី និង ការសាងសង់ទំនប់វារីអគ្គិសនី ដល់ក្រុមហ៊ុនឯកជន ។ ការទាញយកធនធានធម្មជាតិយកទៅប្រើប្រាស់នេះបានផ្តល់នូវគុណសម្បត្តិ និង គុណវិបត្តិទន្ទឹមគ្នា ។ ភាគច្រើនគុណសម្បត្តិ និងប្រាក់ចំណេញបានទៅដល់ម្ចាស់ក្រុមហ៊ុន រីឯគុណវិបត្តិ ឬ ផលប៉ះពាល់បានជះឥទ្ធិពលដល់ប្រជាជនក្រីក្រ ជាពិសេសចំពោះប្រជាជនដែលរស់នៅក្នុងតំបន់នោះផ្ទាល់តែម្តង ។

យ៉ាងណាមិញ នៅក្នុងខេត្តស្ទឹងត្រែង ជាខេត្តភូមិភាគឦសាន ដែលសំបូរទៅដោយធនធានធម្មជាតិនោះ នាពេលបច្ចុប្បន្ន ត្រូវបានទាញយកដើម្បីអភិវឌ្ឍជាច្រើនរូបភាព ជាពិសេសគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេ សេសាន សេកុង ស្រែពក និង ទន្លេមេគង្គ ។ ការអភិវឌ្ឍនេះជាមោទនភាពចំពោះខេត្តស្ទឹងត្រែង និង ប្រទេសកម្ពុជាសំរាប់កំណើនសេដ្ឋកិច្ច ប៉ុន្តែទន្ទឹមនឹងនោះក៏ជាក្តីព្រួយបារម្ភសំរាប់ប្រជាជនដែលរស់នៅតាមដងទន្លេដែលធ្លាប់ពឹងអាស្រ័យការចិញ្ចឹមជីវិតបានមកពីធនធានទន្លេ ។ គម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម ២ ដែលនឹងត្រូវសាងសង់ក្នុងពេលឆាប់ៗខាងមុខនេះ មានកម្លាំង ថាមពល ៤២០មេហ្គាវ៉ាត់ ហើយប្រជាជននៅតាមដងទន្លេសេសាន និង ស្រែពកនឹងត្រូវប៉ះពាល់ និង ជន្លៀសចេញពីភូមិ ។ តើគម្រោងសង់ទំនប់សេសានក្រោម២ នឹងប៉ះពាល់ដល់ប្រជាជននៅតាមដងទន្លេក្នុងខេត្តស្ទឹងត្រែង ដូចម្តេច?

ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់មួយចំនួននោះ គម្រោងគ្រប់គ្រងធនធានទឹក នៃសមាគមថែរក្សាបរិស្ថាន និង វប្បធម៌ (CEPA) បានប្រមូលទិន្នន័យ និង ព័ត៌មានមួយចំនួនរបស់គ្រួសារទាំង ១៥ភូមិ តាមដងទន្លេសេសានក្នុងខេត្តស្ទឹងត្រែង សំរាប់ទុកជាទិន្នន័យដើម និង ជាការវាស់វែងពីទ្រព្យសម្បត្តិនៅក្នុងភូមិ ។ តាមរយៈលទ្ធផលនៃការប្រមូលព័ត៌មាន សង្ឃឹមថានឹងចូលរួមចំណែកក្នុងការផ្ទៀងផ្ទាត់ និង កត់ត្រានូវចំនួនធនធាន និង ទ្រព្យសម្បត្តិរបស់ប្រជាជនដែលមាននៅតាមគ្រួសារ ក្នុងភូមិនីមួយៗតាមដងទន្លេសេសាន ខេត្តស្ទឹងត្រែង ។ម្យ៉ាងទៀតក៏ជាមូលដ្ឋានគ្រឹះសំរាប់អ្នកសិក្សាស្រាវជ្រាវបន្តទៀត សំដៅទៅរកការកាត់បន្ថយនូវផលប៉ះពាល់អោយនៅសល់កំរិតអប្បបរមាបំផុត ។

តាងនាមយើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវ និង ចងក្រងទិន្នន័យនេះ រង់ចាំនូវការកែលំអ មតិយោបល់ និង អនុសាសន៍ពីលោក លោកស្រីអ្នកអាន និង អ្នកស្រាវជ្រាវបន្ត ចំពោះចំណុចខ្វះខាតដែលកើតមានដោយអចេតនា ។

**សូមអរគុណ !**

# Acknowledgment

We would like to say thank you to villagers, Water Resources Management Committee and the local authority in15villages, commune chief in the 5 communes along SeSan River in Stung Treng province that helped us in giving information, cooperation, facilitation and collecting information to get success in this research process.

We would like to say thank you to volunteer staffs that spent their time and energy trying to collect a good data and information.

We would like to say thank you to Mr. Vong Kongkea, Mr. Peak Saven, Ms. Sok Sopheakdey, Ms. Lou Chantha and Ms. Tim Bopha, staff in the Water Resources Management Project and all the colleagues work for Culture and Environment Preservation Association (CEPA) in spending times and energy for editing this report from the beginning of collecting information till the end of reporting writing process.

We would like to say thank you to Mr. Tep Bunnarith, executive director, Mr. Tek Vannara, communication and advocacy program manager, and the leaders in CEPA that facilitate and give us good ideas, advises for research study collecting information to get a good and efficiency result.

We would like to say thank you to Oxfam America that supported fund for this research and other CEPA's activities from the past, present and to the future. This supporting not only a good participating in natural resources and environmental management, or reducing negative impact from large scale developments but also can increases poor Cambodian villagers' livelihood in the remote area along Sesan River.

# Executive Summary

The trends of development in Cambodia now are economic development and poverty reduction in the country. Economic and social development must be equity and transparency that causes all the people both the rich and the poor can use and receive advantages according to their location. To reduce these negative impacts, the Culture and Environment Preservation Association (CEPA) was conducted study on "The livelihood and family's profile of people in 15 villages along the SeSan River". This study is combined river data and livelihood of people for comparing the change of people livelihood and river resources for next year. The information collected in 15villages along Sesan River in Stung Treng province. The methodology used in this research was choosing the volunteers' staff and community water resources in 15 villages to interview the villagers. This study was cooperated with department of environment and department of water resources and meteorology of Stung Treng province, villages and commune authorities. The interviewing, we used the questionnaire to ask all the families in each village, except the families that moved or left from the village.

According to the research result showed that 74. 9 % is the original people living in this village and others are new comers come from other villages in Stung Treng and other provinces. Only 59.7% population was registered. The others didn't register yet. For the head of the family's education showed that 38.2% was illiterate, 5.4% studied in secondary school, 8.7% studied in junior high school and 47.6% studied in elementary school.

There are 8171 people live in these 15 villages. Most of people are social worker such as crop planter: 3797people, animal feeder: 480people, fishermen 21people, Non Timber Forest Products finders: 17 people and student (especially children) 2174 people and the others have other jobs. The time and the seasons of the work have been changed according to the type of the jobs. For the crop planning, they start from May to December. For the animal feeding works in a whole year. The houses were built along the river. Most of those houses are wooden houses with the bamboo or the plank wall. For the poor families the houses were built of bamboo with Tbeng or Sbov leaf roof. For the material using in the house showed that the poor nearly have nothing to use, whereas the rich have many equipments to use in their daily life. In these 15 villages have 509 motors, 75 machine, 23 cars, 2 radars, 52 pumps, 254 rice mills, 37 tractors. For material that nearly all the families have such as 2732 hoes, 1228 jars, 1414 plows, 1285harrows , 1044 bags, 4553 axes and 4432 sickles. For animal feeding showed that most villagers like to feed chicken and duck. Some families feed chicken almost 20-50, whereas pig feeding only 50% of each family in each village. Only 1 to 3 pigs were feted in one family. The total cows are 4847 and the total buffalos are 4068 that people need it for farming purpose. Even thought the amount of the cow and the buffalo more than the villagers, some villagers still didn't have those animals to feed because of their poorness and sometime those animals were died by diseases. Most of the fishing fish along the river in the rainy and dry seasons. They also do fishing in the stream, field, pond or lake in the forest that can be fish in the rainy season. The popular fishing equipments are Morng(web), Santoch, Samnang, Chan, Tom, and the another such as Sayean, True, Lob, Tnos. The villagers live in BanBong, Plok, Srekor I, Srekor II, and RomPort villages like to do fishing along the Sesan River because those villages still have Onlong (deep pool) that is a good natural habitat for the fish living. Unlike those villages, some villages such as Samkoy, Badem, Sesan, Banmay, and Svayreang nearly no fish for eating more. There are no technical or big scale for crop and vegetable growing. They grow it only for supporting their family. The fruits that people like to grow are mango, orange, jackfruit, cashew apple, milk fruit, areca, papaya, corn. The vegetables that people like to grow are cabbage, eggplant, cucumber, pepper, and other tuber plants such as potato, arum. For everyday life, the people collecting Non Timber Forest Products (NTFPs) such as honey, liana, bamboo, bamboo shoot, resin, rattan, wild animal, potato and

mushroom. The villages that depend on NTFPs such as Banbong, plok, Srekor I, Srekor II, Ksarchthmey, Svayreang, Krorlapos, Rompot, and Talat. But those valuable natural resources are serious decreasing because it belongs to the companies and the powerful investors now.

For the land use in the village showed that thought they are live in country side some families don't have their own land to build the house and farming. The importance land sources that people have nowadays are 44.8% from deforestation, 37.24% from their ancestors, 14.70% from public distribution and 3.7% from their own buying. Among the land in the village saw that 74.15% for field farming in rainy season, 5.4 % for growing rice in the field, 4.96% is the housing land, 5.5% is the crop and vegetable field, and others 9.96%. Among these land showed that each family has small land for growing rice so the average yield is only 1171.84 kilograms per hectare. The land use conflict in the village not often happened yet. In sum it has 66 cases that were conflict about the border 43 cases, compete for getting land 18 cases, to invade the land 3 cases, and other conflicts 2 cases.

Most of the family spending on food and buying material for family need. The spending showed that the families that spent lest are 375,000 riels and the families that spend most is 19,497,500 riels per year. So the average for families spending is 4,303,056 riels per year.

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណចំពោះប្រជាជន គណៈកម្មការសហគមន៍គ្រប់គ្រងធនធានទឹក និង អាជ្ញាធរភូមិទាំង ១៥ភូមិ មេឃុំ ក្រុមប្រឹក្សាឃុំទាំង ៥ នៅតាមដងទន្លេសេសាន ខេត្តស្ទឹងត្រែង ដែលបានចូលរួមជួយ ផ្តល់នូវព័តិមាន សហការ និង ជួយសម្របសម្រួលសំរាប់ការសិក្សាស្រាវជ្រាវ និង ប្រមូលព័តិមាននេះមានដំណើរការ ប្រព្រឹត្តទៅមានភាពរលូន និង ទទួលបាននូវលទ្ធផលល្អ ។

សូមថ្លែងអំណរគុណចំពោះក្រុមអ្នកស្ម័គ្រចិត្តក្នុងការប្រមូលព័តិមាន និងបញ្ចូលទិន្នន័យទាំងអស់ ដែលបាន ខិតខំអស់ពីកម្លាំងកាយចិត្ត និង ពេលវេលា ដើម្បីប្រមូលនូវព័តិមានប្រកបដោយគុណភាព និង ប្រសិទ្ធភាព ក្នុងរយៈ ពេលកន្លងមក ។

សូមថ្លែងអំណរគុណចំពោះ លោក វង្ស គង្គា, លោក ពាក្យ សាវ៉ែន, កញ្ញា សុខ សុភក្តិ, កញ្ញា ឡោ ចន្ថា និង កញ្ញា ធីម បុប្ផា បុគ្គលិកគម្រោងគ្រប់គ្រងធនធានទឹក និង បុគ្គលិករួមការងារទាំងអស់នៃ សមាគមថែរក្សាបរិស្ថាន និង វប្បធម៌ (CEPA) ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត និង ពេលវេលា ក្នុងការជួយកែលំអ និង កែសម្រួលនូវពាក្យពេចន៍ ឃ្លាឃ្លោង ប្រយោគ និង ចងក្រងជារបាយការណ៍ ចាប់តាំងពីដំណាក់កាលដំបូង ពេលប្រមូលព័តិមាន ការបញ្ចូលទិន្នន័យ និង ការសរសេរជាលទ្ធផលរបាយការណ៍ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ , លោក ទេព ប៊ុណ្ណារិទ្ធ នាយកប្រតិបត្តិ លោក តឹក វណ្ណារ៉ា ប្រធានកម្មវិធីទំនាក់ទំនង និងតស៊ូមតិ និងថ្នាក់ដឹកនាំអង្គការសេប៉ាដែលបានជួយកែសម្រួល និងផ្តល់ជាគំនិតយោបល់ សំរាប់ការសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ អោយទទួលបាននូវលទ្ធផលប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការអុកស្វាមអាមេរិក (Oxfam America) ដែលបានផ្តល់ ជាថវិកាសំរាប់សកម្មភាពសិក្សាស្រាវជ្រាវនេះ ក៏ដូចជាសកម្មភាពនានារបស់អង្គការសេប៉ា (CEPA) ក្នុងរយៈពេល កន្លងមក ពេលបច្ចុប្បន្ន និងបន្តទៅថ្ងៃមុខទៀត សំរាប់ការចូលរួមថែរក្សានូវធនធានធម្មជាតិ បរិស្ថាន និង កាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ព្រមទាំងបង្កើនជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាដែលមានជីវភាពក្រីក្រនៅតាម តំបន់ដាច់ស្រយាលតាមដងទន្លេសេសាន ។

# សង្ខេបលទ្ធផលសិក្សាស្រាវជ្រាវ

និន្នាការនៃការអភិវឌ្ឍក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងឈានទៅរកកំណើនសេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស អោយបានជាអតិបរមា ។ កំណើនសេដ្ឋកិច្ច និង សង្គមត្រូវមានលក្ខណៈសមធម៌ និង ជាកាលានុវត្តភាព និង ជាផ្លែផ្កា ដែលទាំងអស់គ្នាអាចប្រើប្រាស់ និង ទទួលបានទាំងតាមភូមិសាស្ត្រនីមួយៗ ទាំងសំរាប់អ្នកមាន និង អ្នកក្រ ។ ដើម្បីចូលរួមជួយកាត់បន្ថយផលប៉ះពាល់ ទើបសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ សិក្សាស្រាវជ្រាវពីទិន្នន័យតាមគ្រួសាររបស់ប្រជាជនតាមដងទន្លេសេសាន ក្នុងគោលបំណង សិក្សាពីកំរិតជីវភាពរបស់ប្រជាជននៅតាមដងទន្លេសេសាន និង ស្រែពកសំរាប់ឆ្នាំ ២០០៧ និង ចងក្រងជាទិន្នន័យដើម សំរាប់ធ្វើការវាស់វែង និងផ្ទៀងផ្ទាត់ពីបម្រែបម្រួល នៅឆ្នាំក្រោយៗ ។ ការប្រមូលទិន្នន័យនេះ ធ្វើឡើងនៅភូមិចំនួន ១៥តាមដងទន្លេសេសានក្នុងខេត្តស្ទឹងត្រែង ។ វិធីសាស្ត្រក្នុងការប្រមូលព័ត៌មានគឺជ្រើសរើសក្រុមអ្នកស្ម័គ្រចិត្តសំរាប់ចុះទៅសំភាសន៍ប្រជាជនដោយសហការជាមួយគណៈកម្មការសហគមន៍គ្រប់គ្រងធនធានទឹក និង អាជ្ញាធរភូមិឃុំ ។ ការសំភាសន៍ដោយប្រើបញ្ជីសំណួរសួរទៅគ្រប់គ្រួសារតាមភូមិនីមួយៗ លើកលែងតែគ្រួសារដែលមិននៅក្នុងភូមិ ។

ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវឃើញថាប្រជាជននៅតាមដងទន្លេទាំង ១៥ភូមិ ចំនួន ៧៤,៩ភាគរយ ជាអ្នកមានដើមកំណើតនៅក្នុងភូមិផ្ទាល់តែម្តង និង ក្រៅពីនោះជាអ្នកចំណូលថ្មីមកពីភូមិផ្សេងៗក្នុងខេត្តស្ទឹងត្រែង និងភូមិផ្សេងៗទៀត ។ គ្រួសារទាំងអស់មានតែ ៥៩,៧ភាគរយ ដែលបានចុះបញ្ជីគ្រួសារ និង ក្រៅពីនោះមិនទាន់បានចុះបញ្ជីគ្រួសារ ។ ចំពោះកំរិតវប្បធម៌មេគ្រួសារឃើញថាចំនួន ៣៨,២ភាគរយមិនចេះអក្សរ ហើយមេគ្រួសារដែលបានរៀនសូត្រខ្ពស់ត្រឹមវិទ្យាល័យចំនួន ៥,៤ភាគរយ, អនុវិទ្យាល័យ ៨,៧ភាគរយ និង បឋមសិក្សា ៤៧,៦ ភាគរយ ។

ប្រជាជនទាំងអស់ដែលរស់នៅតាមដងទន្លេទាំង ១៥ភូមិ ចំនួន ៨១៧១នាក់ ភាគច្រើនប្រើកម្លាំងពលកម្មរបស់ខ្លួនសំរាប់ការប្រកបមុខរបរចំបងគឺ ធ្វើស្រែចំការចំនួន ៣៧៩៧នាក់ ចិញ្ចឹមសត្វ ៤៨០នាក់ នេសាទ ២១នាក់ រកផលអនុផលព្រៃឈើ ១៧នាក់ និង អ្នកនៅរៀន (ពិសេសក្មេងៗ)ចំនួន ២១៧៤នាក់ និង ក្រៅពីនោះមានប្រកបមុខរបរផ្សេងៗទៀត ។ ពេលវេលា និង រដូវកាលនៃការប្រកបមុខរបរនេះមានការផ្លាស់ប្តូរទៅតាមប្រភេទ ចំពោះការធ្វើស្រែចំការគឺចាប់ពីខែ ឧសភា ដល់ខែធ្នូ ការចិញ្ចឹមសត្វភាគច្រើនចិញ្ចឹមពេញមួយឆ្នាំ ។ ការសាងសង់លំនៅដ្ឋានគឺធ្វើនៅតាមដងទន្លេ ដែលភាគច្រើនជាប្រភេទផ្ទះឈើប្រក់ស្បូវ ជញ្ជាំងឫស្សី និង ក្តារ ។ ចំពោះគ្រួសារក្រីក្រវិញលំនៅដ្ឋានធ្វើអំពីឫស្សី ប្រក់ស្បូវ ជញ្ជាំងស្លឹកខ្ទង ឬស្លឹកត្នោត ។ សម្ភារៈប្រើប្រាស់ក្នុងផ្ទះតាមគ្រួសារឃើញ ថាគ្រួសារក្រីក្រស្ទើរ តែពុំមានសម្ភារៈសំរាប់ប្រើសោះ រីឯគ្រួសារមាន ជីវភាពធូរធារវិញមានសម្ភារៈច្រើន ។ ភូមិទាំង១៥មានម៉ូតូ ៥០៩ គ្រឿង ម៉ាស៊ីន ៧៥គ្រឿង ឡាន ២៣គ្រឿង ផ្កាយរណប ០២ ម៉ាស៊ីនបូមទឹក ៥២គ្រឿង ម៉ាស៊ីនកិនស្រូវ ២៥៤គ្រឿង គោយន្ត ៣៧គ្រឿង ។ ចំពោះសម្ភារៈដែលមានស្ទើរគ្រប់គ្រួសារនោះគឺ ចបកាប់/ជីក ២៧៣២, ពាង/អាង ១២២៨ នង្គ័ល ១៤១៤, រនាស់ ១២៨៥, កាផា/កន្ត្រក ១០៤៤, ពូថៅ ៤៥៥៣ និង កណ្តៀវ ៤៤៣២ ។ ការចិញ្ចឹមសត្វឃើញថា ភាគច្រើនមានចិញ្ចឹមមាន់ និង ទា ស្ទើរគ្រប់គ្រួសារ ហើយក្នុងគ្រួសារខ្លះមានមាន់ ច្រើនរហូត

ដល់ ២០-៥០ក្បាល ចំណែកសត្វជ្រូកវិញមានចិញ្ចឹមតែ ៥០ភាគរយនៃចំនួនគ្រួសារនៅតាមភូមិ នីមួយៗប៉ុណ្ណោះ ក្នុងនោះមួយគ្រួសារចិញ្ចឹម ពីមួយក្បាលទៅបីក្បាល ។ សត្វគោសរុបចំនួន ៤៨៤៧ក្បាល និង ក្របីសរុបចំនួន ៤០៦៨ក្បាល ដែលប្រជាជនចិញ្ចឹម សំរាប់ជាកម្លាំងអូសទាញនៅពេលធ្វើស្រែចំការ ។ ទោះជាចំនួនសត្វគោក្របីមានចំនួនច្រើនជាងចំនួនគ្រួសាររបស់ ប្រជាជនក្តីប៉ុន្តែក៏នៅមានគ្រួសារដែលគ្មានចិញ្ចឹមសត្វគោក្របីដែរ ដោយសារជីវភាពខ្វះខាត និង ពេលខ្លះត្រូវឈឺងាប់អស់ ។ ការនេសាទភាគច្រើននៅតាមទន្លេទាំងរដូវវស្សា និង រដូវប្រាំង ហើយក្រៅពីនោះនេសាទនៅតាមអូរ និង តាមស្រែ ត្រពាំង ឬស្រះ ដែលអាចនេសាទបាននៅរដូវវស្សា ។ ឧបករណ៍នេសាទភាគច្រើនដែលប្រជាជននេសាទ មានមង សន្ទូច សំណាញ់ ចាន់ តុំ ហើយក្រៅពីនោះមាន សាយឹន ទ្រូ លប ធ្នស់ បន្តិចបន្តួច ។ នៅតាមដងទន្លេសេសាន ភូមិដែលមានការនេសាទច្រើនមានភូមិបានប៊ុង ភ្លុក ស្រែគរ១ ស្រែគរ២ និង ភូមិរំពាត់ប៉ុណ្ណោះ ដោយសារតែភូមិនេះនៅមានអន្លង់ និង តំបន់ជម្រកត្រីច្រើន ក្រៅពីនោះភូមិខ្លះស្ទើរគ្មានត្រីសំរាប់បរិភោគទេដូចជាភូមិសាមឃួយ បាដើម សេសាន បានម៉ៃ និង ភូមិស្វាយរៀង ។ ការធ្វើស្រែចំការ ដាំដំណាំ និង បន្លែនោះជាការដាំសំរាប់បរិភោគនៅក្នុង គ្រួសារប៉ុណ្ណោះ ពុំមានបច្ចេកទេស និង ផ្ទៃដីទ្រង់ទ្រាយធំ សំរាប់ដាំដុះឡើយ ។ ដំណាំហូបផ្លែដែលប្រជាជនចូលចិត្ត ដាំនោះមានដូចជាដូង ស្វាយ ក្រូច ខ្នុរ ចន្ទី ទឹកដោះគោ ស្លា ល្ហុង ចេក ពោត រីឯបន្លែវិញមានដូចជា ស្ពៃ ត្រប់ ត្រសក់ ម្ទេស ហើយ ក្រៅពីនោះមានដំណាំមើមដូចជា ត្រាវ ដំឡូង ។ រៀងរាល់ថ្ងៃនេះប្រជាជននៅតែពឹងផ្អែកទៅលើការរក ផល អនុផលព្រៃឈើដែលមានដូចជា ទឹកឃ្មុំ វល្លិ៍ ឫស្សី ទំពាំង ជ័រទឹក ផ្តៅ សត្វព្រៃ ដំឡូង និង ផ្សិតជាដើម ។ ភូមិដែលនៅរកផលអនុផលព្រៃឈើច្រើនមានភូមិ បានប៊ុង ភ្លុក ស្រែគរ១ ស្រែគរ២ ខ្សាច់ថ្មី ស្វាយរៀង ក្រឡាពុះ រំពាត់ និង តាឡាត ។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះធនធានទាំងនេះត្រូវបានថយចុះយ៉ាងគំហុក ដោយសារតំបន់ដែលធ្លាប់ទៅរកនោះ ត្រូវបានក្លាយជាកម្មសិទ្ធិរបស់ក្រុមហ៊ុន និង អ្នកវិនិយោគធំៗ ។

ការប្រើប្រាស់ដីនៅតាមគ្រួសារនីមួយៗក្នុងភូមិឃើញថា ទោះជានៅតំបន់ជនបទក្តីនៅតែមានគ្រួសារខ្វះខាតដីទាំងសំរាប់លំនៅដ្ឋាន និង សំរាប់ធ្វើស្រែចំការ ។ ប្រភពដីសំខាន់ដែលប្រជាជនមានសព្វថ្ងៃគឺ ៤៤,៨ភាគរយបានពីការកាប់គាស់ព្រៃ ៣៧,២៤ភាគរយបានពីកេរមរតក ១៤,៧០ភាគរយបានពីរដ្ឋចែកអោយ និង ៣,៧ភាគរយបានពីការទិញបន្ថែម ។ ក្នុងចំណោមផ្ទៃដីដែលមាននៅក្នុងភូមិឃើញថា ៧៤,១៥ភាគរយប្រើសំរាប់ធ្វើស្រែវស្សា, ៥,៤ ភាគរយសំរាប់ធ្វើស្រូវចំការ, ៤,៩៦ភាគរយជាដីលំនៅដ្ឋាន, ៥,៥ភាគរយជាដីដាំដំណាំ និង បន្លែ, និង ប្រភេទដីផ្សេងៗចំនួន ៩,៩៦ភាគរយ ។ ក្នុងចំណោមផ្ទៃដីធ្វើស្រែឃើញថាតាមគ្រួសារនីមួយៗមានផ្ទៃដីតូច ហើយផលដែលទទួលបានជាមធ្យមចំនួន ១១៧១,៨៤គីឡូក្រាមក្នុងមួយហិកតា ។ ទំនាស់ដីធ្លីតាមភូមិនៅមិនទាន់មានកើតឡើងច្រើនទេ បើធ្វើការសរុបទំនាស់ដីធ្លីមានចំនួន ៦៦ករណី ក្នុងនោះទំនាស់ព្រំដី ៤៣ករណី, ការដណ្តើម យកដី ១៨ករណី, ការរានដី ៣ ករណី និង ទំនាស់ផ្សេងៗ ២ករណី ។

ការចំណាយក្នុងគ្រួសារភាគច្រើនចំណាយទៅលើម្ហូបអាហារ និង ទិញសម្ភារៈក្នុងគ្រួសារ ។ ជាមធ្យមចំណាយនៅក្នុងគ្រួសារនីមួយៗ ជារួមឃើញថាគ្រួសារដែលមានចំណាយតិចជាងគេប្រចាំឆ្នាំនោះត្រឹមចំនួន ៣៧៥.០០០ រៀល និង គ្រួសារដែលមានចំណាយខ្ពស់ជាងគេ ក្នុង គ្រួសារនោះមានរហូតដល់ទៅ ១៩.៤៩៧.៥០០ រៀលក្នុងមួយឆ្នាំ ជាមធ្យម ឃើញថាចំណាយក្នុងគ្រួសារចំនួន ៤.៣០៣.០៥៦ រៀលក្នុងមួយឆ្នាំ ។

# មាតិកា

**ទំព័រ**


- អារម្ភកថា ........................................ i
- សេចក្តីថ្លែងអំណរគុណ ........................................ v
- សង្ខេបលទ្ធផលសិក្សាស្រាវជ្រាវ ........................................ vi
- មាតិកា ........................................ viii
- បញ្ជីរូបភាព ........................................ ix
- បញ្ជីអក្សរកាត់ ........................................ xi

**១. សេចក្តីផ្តើម ........................................ ១**

១.១ ព័ត៌មានទូទៅ ........................................ ១

១.២ គោលបំណង ........................................ ២

១.៣ ទំហំនៃការសិក្សា ........................................ ២

**២. វិធីសាស្ត្រប្រមូលព័ត៌មាន ........................................ ៣**

២.១ ការជ្រើសរើសអ្នកប្រមូលព័ត៌មាន ........................................ ៣

២.២ ការប្រមូលព័ត៌មាន ........................................ ៣

២.៣ ការវិភាគទិន្នន័យ និងសរសេររបាយការណ៍ ........................................ ៤

**៣. លទ្ធផលនៃការសិក្សាស្រាវជ្រាវ ........................................ ៥**

៣.១ ព័ត៌មានទូទៅ ........................................ ៥

៣.១.១ ស្ថានភាពភូមិសាស្ត្រ ........................................ ៥

៣.១.២ ការមកតាំងទីលំនៅក្នុងភូមិ ........................................ ៥

៣.១.៣ ការអប់រំ និង អាយុរបស់មេគ្រួសារ ........................................ ៦

៣.១.៤ ការប្រកបមុខរបរ ........................................ ៨

៣.១.៥ រដូវកាលនៃការប្រកបមុខរបរ ........................................ ១១

៣.២ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារក្នុងភូមិនីមួយៗ ........................................ ១២

៣.៣ សម្ភារៈប្រើប្រាស់នៅក្នុងផ្ទះ ........................................ ២៣

៣.៤ ការប្រកបមុខរបរ ........................................ ២៥

៣.៤.១ ការចិញ្ចឹមសត្វតាមគ្រួសារ ........................................ ២៥

៣.៤.២ ឧបករណ៍នេសាទ ........................................ ៣០

៣.៤.៣ ការដាំដុះដំណាំ និង បន្លែ ........................................ ៣២

៣.៤.៤ ការរកផល អនុផលព្រៃឈើ ........................................ ៣៦

៣.៥ ព័ត៌មានដីនៅក្នុងភូមិទាំង ១៥ ........................................ ៣៧

៣.៥.១ ទំហំ

ប្រភព និង ប្រភេទដីតាមភូមិនីមួយៗ ........................................ ៣៧

៣.៥.២ ផលិតផល

លរបស់ដីតាមភូមិនីមួយៗ ........................................ ៣៨

៣.៦ ទំនាស់ដីធ្លីតាមភូមិ ........................................ ៣៩

៣.៧ ចំណាយប្រចាំគ្រួសារជាមធ្យម ក្នុងភូមិទាំង ១៥ ........................................ ៤០

**៤. សន្និដ្ឋាន ........................................ ៤២**

**៥. ឯកសារយោង........................................ ៤៣**

## បញ្ជីវិចិត្ររូប

| **ល.រ** | **ចំណងជើង** | | | **ទំព័រ** |
|---|---|---|---|---|

### តារាង


០១ តារាង ១ ចំនួនគ្រួសារដែលបានសំភាសន៍ក្នុងភូមិ ១៥ តាមដងទន្លេសេសាន ........................ ៣

០២ តារាង ២ ចំណាត់ថ្នាក់កំរិតវប្បធម៌ ធៀបនឹងចន្លោះអាយុមេគ្រួសារទាំង ១៥ភូមិ ........................ ៦

០៣ តារាង ៣ ចំនួនកម្លាំងពលកម្មតាមប្រភេទមុខរបរក្នុងភូមិនីមួយៗ ........................ ៩

០៤ តារាង ៤ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិសាមឃួយ ........................ ១២

០៥ តារាង ៥ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិបាដើម ........................ ១២

០៦ តារាង ៦ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិហាងសាវ៉ាត ........................ ១៣

០៧ តារាង ៧ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិសេសាន ........................ ១៤

០៨ តារាង ៨ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិបានម៉ៃ ........................ ១៤

០៩ តារាង ៩ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិកំភុន ........................ ១៤

១០ តារាង ១០ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិបានប៊ុង ........................ ១៥

១១ តារាង ១១ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិភ្លុក ........................ ១៦

១២ តារាង ១២ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិស្រែគរ១ ........................ ១៧

១៣ តារាង ១៣ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិស្រែគរ២ ........................ ១៨

១៤ តារាង ១៤ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិខ្សាច់ថ្មី ........................ ១៩

១៥ តារាង ១៥ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិស្វាយរៀង ........................ ១៩

១៦ តារាង ១៦ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិក្រឡាពុះ ........................ ២០

១៧ តារាង ១៧ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិរំពាត់ ........................ ២១

១៨ តារាង ១៨ ប្រភេទផ្ទះ និង ជម្រកផ្សេងៗនៅក្នុងគ្រួសារ ភូមិតាឡាត ........................ ២២

១៩ តារាង ១៩ ចំនួនគ្រួសារ និង ប្រភេទសម្ភារៈប្រើប្រាស់ក្នុងភូមិទាំង ១៥ ........................ ២៣

២០ តារាង ២០ ចំនួនសម្ភារះប្រើប្រាស់ក្នុងភូមិទាំង ១៥ .............................................................. ២៦
២១ តារាង ២១ ការចិញ្ចឹមសត្វតាមគ្រួសារទាំង ១៥ភូមិ .............................................................. ២៩
២២ តារាង ២២ គ្រួសារដែលមានប្រភេទឧបករណ៍នេសាទក្នុងភូមិទាំង ១៥ ........................................ ៣០
២៣ តារាង ២៣ ចំនួនឧបករណ៍នេសាទតាមគ្រួសារ .............................................................. ៣១
២៤ តារាង ២៤ ចំនួនគ្រួសារដែលដាំដុះដំណាំ និង បន្លែ .............................................................. ៣២
២៥ តារាង ២៥ ចំនួនដំណាំ និង បន្លែតាមគ្រួសារ .............................................................. ៣៤
២៦ តារាង ២៦ ចំនួនគ្រួសារដែលរកផល អនុផលព្រៃឈើទាំង ១៥ភូមិ ........................................ ៣៦
២៧ តារាង ២៧ ទំហំ ប្រភព និង ប្រភេទដីតាមភូមិនីមួយៗ .............................................................. ៣៧
២៨ តារាង ២៨ ផលិតផលដីតាមភូមិ .............................................................. ៣៨
២៩ តារាង ២៩ ប្រភេទទំនាស់ដីធ្លីតាមភូមិនីមួយៗ .............................................................. ៣៩
៣០ តារាង ៣០ ចំណាយប្រចាំគ្រួសារជាមធ្យម ក្នុងភូមិទាំង ១៥ .............................................................. ៤០

## ក្រាហ្វិក

៣១ ក្រាហ្វិក ១ ភាគរយចន្លោះឆ្នាំនៃការតាំងទីលំនៅរបស់គ្រួសារ ១៥ភូមិ ........................................ ៥
៣២ ក្រាហ្វិក ២ ភាគរយការចុះបញ្ជីគ្រួសារ ១៥ភូមិ .............................................................. ៥
៣៣ ក្រាហ្វិក ៣ ភាគរយកំរិតវប្បធម៌មេគ្រួសារ ១៥ភូមិ .............................................................. ៦
៣៤ ក្រាហ្វិក ៤ ភាគរយកំរិតវប្បធម៌មេគ្រួសារ ១៥ភូមិ .............................................................. ៦
៣៥ ក្រាហ្វិក ៥ ភាគរយប្រភេទនៃទំនាស់ដីធ្លី .............................................................. ៣៩

## ឧបសម្ព័ន្ធ

៣៦ បញ្ជីឈ្មោះ ក្រុមអ្នកសិក្សាស្រាវជ្រាវទិន្នន័យគ្រួសារ នៅតាមដងទន្លេសេសាន និងស្រែពក ខេត្តស្ទឹងត្រែង............. ៤៤
៣៧ រូបថតទាក់ទងនឹងស្ថានភាពជីវភាពរស់នៅរបស់អ្នកភូមិតាមដងទន្លេសេសាន.................................................. ៥៣

# បញ្ជីអក្សរកាត់

| ពាក្យសរសេរកាត់ | ពាក្យពេញលេញ |
| --- | --- |
| - ល.រ | លេខរៀង |
| - គក្រ | គីឡូក្រាម |
| - <= | តូចជាងឬស្មើ |
| - >= | ធំជាងឬស្មើ |

# ១. សេចក្តីផ្តើម

## ១.១ ព័ត៌មានទូទៅ

និន្នាការនៃការអភិវឌ្ឍក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងឈានទៅរកកំណើនសេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស អោយបានជាអតិបរមា ។ ដោយពង្រឹង និង ស្ថាបនា លើមូលដ្ឋាននៃសមិទ្ធិផលទាំងឡាយដែលសម្រេចបានពីពេលមុនៗ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្ត ដើម្បីសម្រេចគោលដៅសហស្សវត្សរ៍កម្ពុជាឆ្នាំ ២០១៥ ដែលផ្តោតលើការអភិវឌ្ឍមនុស្សជាតិតាមរយៈ យុទ្ធសាស្ត្រចតុកោណ បន្តពីយុទ្ធសាស្ត្រត្រីកោណ របស់រាជរដ្ឋាភិបាលសម្រាប់គោលដៅរួម ដែលមានការរៀបចំគិតគូរច្បាស់លាស់ ក៏ដូចជាសំរាប់ការវិនិយោគ និង កំណើនចំពោះបណ្តាវិស័យអាទិភាព ។ កំណើនសេដ្ឋកិច្ច និង សង្គមត្រូវមានលក្ខណៈសមធម៌ និង ជាកាលានុវត្តភាព និង ជាផ្លែផ្កា ដែលទាំងអស់គ្នាអាចប្រើប្រាស់ និង ទទួលបានទាំងតាមភូមិសាស្ត្រនីមួយៗ ទាំងសំរាប់អ្នកមាន និង អ្នកក្រ ។ យើងត្រូវប្រើប្រាស់ធនធានដ៏តិចតួចស្តួចស្តើង ដើម្បីផលប្រយោជន៍ជាអតិបរមារបស់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសសម្រាប់អ្នកក្រីក្រ យើងមិនត្រូវទុកអោយការវិនិយោគក្នុងវិស័យសាធារណៈជាជម្រើស ឬការសម្រេចចិត្តរបស់អ្នកក្រៅផ្សេងឡើយ ( *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*) ។

ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺសំដៅលើកកម្ពស់គុណភាពជីវភាពប្រជាជន និង កាត់បន្ថយភាពក្រីក្រ ។ ក្នុងចំណោមវិស័យអាទិភាពទាំងនោះភាគច្រើនគឺផ្អែកទៅលើការទាញយកធនធានធម្មជាតិមកធ្វើការអភិវឌ្ឍ ដូចជានៅក្នុងមុំទីមួយដែលផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្ម ដែលក្នុងនោះរួមមានៈ ១-លើកកម្ពស់ផលិតភាព និង ពិពិធកម្ម[១] វិស័យកសិកម្ម, ២-កំណែទំរង់ដីធ្លី ការបោសសំអាតមីន, ៣-កំណែទំរង់វិស័យនេសាទ និង ជលផល និង ៤-កំណែទំរង់ព្រៃឈើ ។ ការទាញយកធនធានធម្មជាតិមកធ្វើការអភិវឌ្ឍរបស់កម្មវិធីវិនិយោគមួយចំនួនដែលបានធ្វើការសិក្សា និង វាយតម្លៃអោយបានត្រឹមត្រូវតាមបច្ចេកទេសពីផលប៉ះពាល់ដល់សង្គម និង បរិស្ថាន និង អោយមានការចូលរួមសំរេចចិត្តពីអ្នករស់នៅក្នុងតំបន់នោះ ពិតជាធ្វើអោយការអភិវឌ្ឍមានភាពរីកចំរើន និង មាននិរន្តរភាព ។ ប៉ុន្តែផ្ទុយទៅវិញសកម្មភាពអភិវឌ្ឍន៍មួយចំនួនមិនបានធ្វើការសិក្សា និង វាយតម្លៃហេតុផលប៉ះពាល់អោយបានត្រឹមត្រូវនោះទេ ដូចជាការផ្តល់ដីសម្បទាន និង ព្រៃសម្បទាន, ការសាងសង់ទំនប់វារីអគ្គិសនីរបស់ប្រទេសជិតខាង បានធ្វើអោយមានផលប៉ះពាល់យ៉ាងច្រើនដល់បរិស្ថាន សេដ្ឋកិច្ចសង្គម និង ប្រជាជននៅក្នុងតំបន់ ជាពិសេសចំពោះប្រជាជនក្រីក្រ ជនជាតិដើមភាគតិច និង ក្រុមងាយរងគ្រោះជាច្រើន ។

យ៉ាងណាមិញនៅក្នុងខេត្តស្ទឹងត្រែង ដែលជាខេត្តមួយក្នុងចំណោមខេត្តទាំង ៣ ក្នុងភូមិភាគឦសានក្នុងប្រទេសកម្ពុជា ដែលបាន និង កំពុងធ្វើការអភិវឌ្ឍ ហើយនឹងមានផែនការសំរាប់អភិវឌ្ឍន៍នៅក្នុងខេត្តជាច្រើនទៀត ដូចជាការផ្តល់ដី និង ព្រៃសម្បទានដល់ក្រុមហ៊ុនឯកជន, ការសាងសង់ផ្លូវជាតិលេខ ៧ ពីខេត្តក្រចេះដល់ព្រំប្រទល់កម្ពុជាឡាវ, ការជីករករ៉ែត្បូងថ្ម ហើយជាពិសេសជាងនេះទៅទៀតនោះ នឹងមានគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតាម

[១] អំពើ ឬ សកម្មភាពផ្សេងៗគ្នា, សកម្មភាពច្រើនបែបច្រើនយ៉ាង

ដងទន្លេសេសាន សេកុង ស្រែពក និង ទន្លេមេគង្គ ។ គម្រោងអភិវឌ្ឍន៍ទាំងនេះ មានគម្រោងមួយចំនួនមិនបានធ្វើការសិក្សាអោយបានត្រឹមត្រូវទៅតាមស្តង់ដារបច្ចេកទេស ដែលបង្កអោយមានផលប៉ះពាល់ជាច្រើននៅក្នុងតំបន់ ។

ចំពោះប្រជាជននៅតាមដងទន្លេសេសាន និង ស្រែពក ធ្លាប់បាន និង កំពុងទទួលរងនូវផលប៉ះពាល់ដោយសារការសាងសង់ទំនប់វារីអគ្គិសនីនៅប្រទេសវៀតណាមចាប់តាំងពីឆ្នាំ ១៩៩៦ រហូតមកដល់ពេលបច្ចុប្បន្ននេះ ។ នៅថ្ងៃខាងមុខនឹងមានគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេទាំងនេះក្នុងប្រទេសកម្ពុជា ហើយគម្រោងនេះបើមិនធ្វើការសិក្សាពីផលប៉ះពាល់អោយបានត្រឹមត្រូវទេនោះ ប្រជាជននៅតាមដងទន្លេនឹងជួបប្រទះនូវផលប៉ះពាល់ទាំងនេះកាន់តែខ្លាំងថែមទៀត ។ ដើម្បីធ្វើការផ្ទៀងផ្ទាត់ និង វាស់វែងនូវបំរែបំរួលធនធានដែលមាននៅក្នុងគ្រួសារ និង នៅក្នុងភូមិតាមដងទន្លេនោះ ទើបគម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលដល់សហគមន៍ និង អ្នកពាក់ព័ន្ធពីរបៀបកត់ត្រា និង ប្រមូលព័ត៌មានដែលមាននៅតាមភូមិនីមួយៗរបស់ខ្លួន ហើយនឹងតំរូវអោយអ្នកចូលរួមទាំងអស់យកទៅអនុវត្តនៅក្នុងសហគមន៍ និង ភូមិ ឃុំរបស់ខ្លួនតាមទន្លេសេសាន និង ស្រែពក ។

## ១.២ គោលបំណង

- លើកកម្ពស់ចំណេះដឹងសហគមន៍ និង អ្នកពាក់ព័ន្ធពីរបៀបប្រមូលព័ត៌មាននៅក្នុងគ្រួសារ និង ក្នុងភូមិ
- ដើម្បីសិក្សាពីគំរិតជីវភាពរបស់ប្រជាជននៅតាមដងទន្លេសេសាន និង ស្រែពកសំរាប់ឆ្នាំ ២០០៧
- ចងក្រងជាទិន្នន័យដើម សំរាប់ធ្វើការវាស់វែង និង ផ្ទៀងផ្ទាត់ពីបម្រែបម្រួល នៅឆ្នាំក្រោយៗ

## ១.៣ ទំហំនៃការសិក្សាស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ ទៅលើភូមិចំនួន ១៥ ភូមិ (ភូមិនៅក្នុងរដ្ឋបាលមានតែ ១៤ ដោយសារភូមិក្រឡាពុះ និង ភូមិស្វាយរៀងជាភូមិតែមួយ) ក្នុងឃុំចំនួន ៥ នៅតាមដងទន្លេសេសាន ក្នុងខេត្តស្ទឹងត្រែង ។ ការសំភាសន៍តាមភូមិនីមួយៗ ជ្រើសរើសយកចំនួនប្រជាជនគ្រប់គ្រួសារទាំងអស់ ប៉ុន្តែមានភូមិខ្លះសំភាសន៍មិនបានគ្រប់ចំនួនគ្រួសារតាមភូមិនីមួយៗ ដោយសារគ្រួសារប្រជាជនទាំងនោះមិននៅផ្ទះ ឬ នៅស្រែឆ្ងាយ ។

# ២. វិធីសាស្ត្រប្រមូលព័ត៌មាន

## ២.១ ការជ្រើសរើសអ្នកប្រមូលព័ត៌មាន

ការប្រមូលទិន្នន័យធ្វើឡើងដោយគណៈកម្មការសហគមន៍គ្រប់គ្រងធនធានទឹកតាមភូមិនីមួយៗ មេភូមិ មេឃុំ និង ក្រុមអ្នកស្ម័គ្រចិត្តដែលបានជ្រើសរើសនៅក្នុងខេត្តស្ទឹងត្រែង ។ គណៈកម្មការសហគមន៍តាមភូមិនីមួយៗ គឺជ្រើសរើសយកគណៈកម្មការដែលមានសមត្ថភាពក្នុងការសួរនាំ និង សរសេរអក្សរបាន ។ មេភូមិ មេឃុំ គឺជាអ្នកជួយសម្របសម្រួលការងារ នៅពេលដែលក្រុមអ្នកស្ម័គ្រចិត្តចុះទៅប្រមូលនៅតាមភូមិរបស់ខ្លួន ។ ក្រុមអ្នកស្ម័គ្រចិត្តមុននឹងបានចូលរួមជាក្រុមសំរាប់ប្រមូលព័ត៌មានត្រូវឆ្លងកាត់ការធ្វើតេស្តពីរលើក លើកទីមួយធ្វើតេស្តដោយសរសេរ និង លើកទីពីរធ្វើតេស្តផ្ទាល់មាត់ ។

ក្រោយពីជ្រើសរើសបានគណៈកម្មការតាមភូមិនីមួយៗ និង ក្រុមអ្នកស្ម័គ្រចិត្តរួចមក បុគ្គលិកគម្រោងគ្រប់គ្រងធនធានទឹកបានបើកវគ្គបណ្តុះបណ្តាលពីវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និង ការអង្កេតនៅពេលចុះសំភាសន៍នៅតាមភូមិ ដោយលើកបញ្ជីសំណួរមកពន្យល់ណែនាំ និង បង្ហាញពីរបៀបកត់ត្រាចូលទៅក្នុងបញ្ជីសំណួរ ។

## ២.២ ទំហំសំណាកប្រមូលព័ត៌មាន

តាមគោលបំណងនៃការប្រមូលព័ត៌មាននេះធ្វើឡើងដើម្បីប្រមូលនូវទិន្នន័យគ្រួសារតាមភូមិគ្រប់គ្រួសារ ទាំងចំនួនមនុស្ស ប្រភេទមុខរបរ សម្ភារៈ ដីធ្លី និង ទ្រព្យសម្បត្តិ ។ គ្រប់ភូមិទាំង ១៥ ត្រូវធ្វើការសំភាសន៍គ្រប់គ្រួសារទាំងអស់ ដោយស្រង់យកចំនួនគ្រួសារពីមេភូមិ មេឃុំ បន្ទាប់មកក្រុមអ្នកប្រមូលព័ត៌មានចុះសំភាសន៍ផ្ទាល់ ។ នៅក្នុងការសំភាសន៍គ្រួសារខ្លះត្រូវបានជួបសំភាសន៍នៅក្នុងភូមិ និង គ្រួសារខ្លះទៀតត្រូវចុះទៅសំភាសន៍ដល់វាលស្រែ ដែលប្រជាជនស្នាក់នៅកំលុងពេលធ្វើស្រែចំការ ។ ទោះជាការសំភាសន៍ព្យាយាមប្រមូលព័ត៌មានអោយគ្រប់គ្រួសារតាមភូមិក្តី ប៉ុន្តែក៏នៅតែមិនបានសំភាសន៍អោយគ្រប់គ្រួសារទាំងអស់ដែរ ដោយសារគ្រួសារទាំងនោះមិននៅក្នុងភូមិ និង ខ្លះទៀតធ្វើស្រែចំការនៅឆ្ងាយពីភូមិ ។ ជាលទ្ធផលនៃការប្រមូលព័ត៌មាន សំភាសន៍បានគ្រួសារចំនួន ១៥៣០គ្រួសារ នៅក្នុងភូមិ ១៥ ឃុំទាំង ៥ តាមដងទន្លេសេសាន ខេត្តស្ទឹងត្រែង ។

**តារាង ចំនួនគ្រួសារដែលបានសំភាសន៍ក្នុងភូមិ ១៥ តាមដងទន្លេសេសាន**

| ល.រ | ភូមិ | ចំនួនគ្រួសារសរុប | ចំនួនគ្រួសារសំភាសន៍ |
|---|---|---|---|
| ១ | សាមឃួយ | ១១៤ | ៩២ |
| ២ | បាដើម | ១៣១ | ១០០ |
| ៣ | ហាងសាវ៉ាត | ១៣៧ | ១០០ |
| ៤ | សេសាន | ៧៣ | ៦៥ |
| ៥ | បានម៉ៃ | ៩៦ | ៩៤ |
| ៦ | កំភុន | ៣៣៧ | ២៤៧ |
| ៧ | បានប៊ុង | ៦២ | ៦២ |

| | | | |
|---|---|---|---|
| ៨ | ភ្លុក | ១៧៥ | ១៤២ |
| ៩ | ស្រែគរ១ | ១៦៥ | ១០០ |
| ១០ | ស្រែគរ២ | ១៥៨ | ១០១ |
| ១១ | ខ្សាច់ថ្មី | ២៦៩ | ១៧១ |
| ១២ | ស្វាយរៀង | ២០៧ | ១៦៦ |
| ១៣ | ក្រឡាពុះ | ៤៩ | ៣៤ |
| ១៤ | រំពាត់ | ៥១ | ៣៣ |
| ១៥ | តាឡាត | ៧១ | ៣៩ |
| សរុប | | ២០៩៥ | ១៥៤៦ |

## ២.៣ ការវិភាគទិន្នន័យ និង សរសេររបាយការណ៍

ទិន្នន័យដែលសំភាសន៍បាននៅក្នុងបញ្ជីសំណួរ ត្រូវបានយកមកបញ្ចូលទៅក្នុងកុំព្យូទ័រកម្មវិធី Microsoft Excel ដោយមានបែងចែកទៅតាមសន្ទស្សន៍ និង ប្រភេទនៃព័ត៌មានតាមបញ្ជីសំណួរនីមួយៗ ដើម្បីងាយស្រួលក្នុងការវិភាគ ។ នៅក្នុងការវិភាគទិន្នន័យប្រើតាមកម្មវិធី Microsoft Excel and SPSS ។ ក្រោយពីវិភាគឃើញនូវលទ្ធផលទិន្នន័យព័ត៌មាននីមួយៗ យកមកធ្វើការពន្យល់បង្ហាញតាមរយៈតារាង ក្រាហ្វិក និង សរសេរបរិយាយបន្ថែម ។

# ៣. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅ

### ៣.១.១ ស្ថានភាពភូមិសាស្ត្រ

ទន្លេសេសាន ជាទន្លេមួយក្នុងចំណោមទន្លេទាំង ៤ក្នុងខេត្តស្ទឹងត្រែង មានប្រភពពីប្រទេសវៀតណាម ហូរកាត់ខេត្តរតនគីរី និង បញ្ចប់នៅខេត្តស្ទឹងត្រែង ដោយហូរចូលទៅក្នុងទន្លេសេកុង នៅក្នុងភូមិសាមឃួយ ឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង ។ នៅតាមដងទន្លេសេសានក្នុងខេត្តស្ទឹងត្រែងមានប្រជាជនរស់នៅចំនួន ១៥ ភូមិគឺភូមិសាមឃួយ បាដើម ហាងសាវ៉ាត ឃុំសាមឃួយ, ភូមិសេសាន បានម៉ៃ កំភុន ឃុំកំភុន, ភូមិភ្លុក បានប៊ុង ឃុំ ភ្លុក, ភូមិស្រែគរ១ ស្រែគរ២ ឃុំស្រែគរ, ភូមិខ្សាច់ថ្មី ស្វាយរៀង ក្រឡាពុះ រំពាត់ និង តាឡាត ឃុំតាឡាត ក្នុងស្រុក សេសាន ខេត្តស្ទឹងត្រែង ។

### ៣.១.២ ការមកតាំងទីលំនៅក្នុងភូមិ

ប្រជាជននៅតាមដងទន្លេសេសាន ក្នុងខេត្តស្ទឹងត្រែង ភាគច្រើនជាអ្នកដែលមានដើមកំណើតនៅទីនោះផ្ទាល់តែម្តង និង មានមួយចំនួនតូចដែលជាអ្នកចំណូលថ្មីមកពីភូមិផ្សេងៗនៅក្នុងខេត្តស្ទឹងត្រែង និងគ្រួសារខ្លះមកពីខេត្តផ្សេងៗ មានខេត្តរតនគីរី ព្រះវិហារ តាកែវ កំពង់ចាម កំពង់ស្ពឺ កណ្តាល កំពង់ធំ ក្រចេះ ពោធិ៍សាត់ មណ្ឌលគីរី និង អ្នក មកពីប្រទេសឡាវ ។ ប្រជាជនចំណូលថ្មីចូលមករស់នៅក្នុងភូមិទាំងនេះ ដោយសារមូលហេតុ ការរកស៊ីជួញដូរ ការរៀបអាពាហ៍ពិពាហ៍ កម្មករសំណង់ មន្ត្រីរាជការ ទាហានខ្មែរក្រហមធ្វើសមាហរណកម្មមកពីអន្លង់វែងខេត្តព្រះវិហារ និង ប្រជាជនខ្លះខ្លះ ដីធ្វើស្រែចំការ ។ តាមទិន្នន័យសិក្សាឃើញថាគ្រួសារដែលមានដើមកំណើតនៅក្នុងភូមិរបស់ខ្លួនមានចំនួន ១១៥៨ គ្រួសារ និង គ្រួសារដែលបានចូលមកពីខាងក្រៅមានចំនួន ៣៨៨គ្រួសារ ( ក្រាហ្វិក) ។



*ក្រាហ្វិក ភាគរយចន្លោះឆ្នាំនៃការតាំងទីលំនៅរបស់គ្រួសារ ១៥ភូមិ*

ម្យ៉ាងទៀត ចំពោះការចុះបញ្ជីគ្រួសាររបស់ប្រជាជននៅតាមដងទន្លេសេសានទាំង ១៥ភូមិ ខុសៗគ្នា ពោលគឺចាប់ផ្តើមចុះចាប់ពីឆ្នាំ ១៩៩៤ រហូតមកដល់ឆ្នាំ ២០០៧ ។ ជាមួយគ្នានោះក៏មានគ្រួសារដែលនៅមិនទាន់បានចុះបញ្ជីគ្រួសារចំនួន ៤០,៣ភាគរយ ដោយសារ ពិបាកក្នុងការចូលរួមព្រោះនៅរដូវធ្វើស្រែចំការ ប្រជាជនដែលស្ថិតនៅតាមស្រែជាប្រចាំជាមធ្យមមានរយៈពេល ៦ ទៅ ៨ខែ ជាពិសេសភូមិតាឡាត រំពាត់ និង ស្រែគរ ( ក្រាហ្វិក) ។



*ក្រាហ្វិក ភាគរយការចុះបញ្ជីគ្រួសារ ១៥ភូមិ*

### ៣.១.៣ ការអប់រំ និង អាយុរបស់មេគ្រួសារ

ប្រជាជននៅតាមដងទន្លេសេសានទាំង ១៥ភូមិ ជាពិសេសមេគ្រួសារឃើញថាកំរិតវប្បធម៌ខ្ពស់បំផុតបានរៀនត្រឹមតែ ថ្នាក់ទី ១២ប៉ុណ្ណោះ ។ ចំពោះមេគ្រួសារដែលបានរៀនដល់វិទ្យាល័យនោះមានតែមេគ្រួសារដែលទើបរៀបការក្រោយរបបប៉ុលពតប៉ុណ្ណោះ ដែលមានចន្លោះអាយុចាប់ពី ១៨ឆ្នាំ ទៅ ៤៥ឆ្នាំ ។ ចំពោះមេគ្រួសារដែលរៀបចំគ្រួសារមុនរបបប៉ុលពតនោះមិនបានរៀនដល់កំរិតវិទ្យាល័យទេ ដោយសារតែនៅសម័យនោះមានសង្គ្រាមច្រើន ខ្វះសាលារៀន និង សាលារៀននៅឆ្ងាយពីភូមិ ភាគច្រើនរៀន និង បួសរៀននៅតាមវត្តអារាម ។



*ក្រាហ្វិក ភាគរយកំរិតវប្បធម៌មេគ្រួសារ ១៥ភូមិ*



*ក្រាហ្វិក ភាគរយកំរិតវប្បធម៌មេគ្រួសារ ១៥ភូមិ*

អាយុមេគ្រួសារនៅក្នុងភូមិទាបបំផុតត្រឹមអាយុ ១៨ឆ្នាំ និង ខ្ពស់បំផុតមានដល់ ៨៧ឆ្នាំ ។ ក្នុងចន្លោះអាយុមេគ្រួសារទាំង ១៥ភូមិចាប់ពី ១៨ឆ្នាំ ដល់ ៨៧ឆ្នាំ ឃើញថាភាគច្រើនជាកម្លាំងពលកម្មពេញគឺអាយុពី ២៦ឆ្នាំ ទៅ ៤៥ឆ្នាំ មានចំនួន ៥២ភាគរយ ។ មេគ្រួសារដែលមានអាយុតិចជាង ២៥ឆ្នាំ ច្រើនមាននៅក្នុងភូមិក្រឡាពុះ និង ភូមិរំពាត់ ឃុំ តាឡាត ជាភូមិជនជាតិដើមភាគតិចគ្រឹង ។ រហូតមកដល់ពេលនេះជនជាតិដើម ភាគតិចនៅភូមិរំពាត់មានទំនៀមទំលាប់ឆាប់រៀបចំគូស្រករ (រៀបចំគ្រួសារ) នៅអាយុក្មេងៗ ជាពិសេសស្ត្រីចាប់ពីអាយុ១៦ឆ្នាំឡើងទៅរហូតដល់អាយុ ២៥ឆ្នាំ ។ បើស្ត្រីនៅក្នុងភូមិមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅមានន័យថាពិបាកនឹងមានគេចូលស្តីដណ្តឹង ។

**តារាង ចំណាត់ថ្នាក់កំរិតវប្បធម៌ ធៀបនឹងចន្លោះអាយុមេគ្រួសារទាំង ១៥ភូមិ**

| PUmi | kMritvb,Fm’ | cenøaHGayuemRKYsar ¬nak;¦ | | | | srub |
|---|---|---|---|---|---|---|
| | | <=២៥ | ២៦-៤៥ | ៤៦-៦៥ | >=៦៦ | |
| បាដើម | 0 | ១ | ១៣ | ១៦ | ១១ | ៤១ |
| | ១-៦ | ២ | ២៤ | ១៣ | ៤ | ៤៣ |
| | ៧-៩ | 0 | ៩ | ២ | 0 | ១១ |
| | ១០-១២ | 0 | ១ | ១ | ១ | ៣ |
| | សរុប | ៣ | ៤៧ | ៣២ | ១៦ | ៩៨ |
| បានប៉ុង | 0 | ១ | ១០ | ៣ | ៤ | ១៨ |
| | ១-៦ | ៤ | ២០ | ៩ | 0 | ៣៣ |
| | ៧-៩ | 0 | ៥ | ៣ | ១ | ៩ |

| | | | | | | |
|---|---|---|---|---|---|---|
| | ១០-១២ | ០ | ១ | ៤ | ០ | ៥ |
| | សរុប | ៥ | ៣៦ | ១៩ | ៥ | ៦៥ |
| បានម៉ែ | ០ | ៦ | ១៩ | ១៣ | ៣ | ៤១ |
| | ១-៦ | ៧ | ២០ | ១៤ | ១ | ៤២ |
| | ៧-៩ | ២ | ៣ | ០ | ១ | ៦ |
| | ១០-១២ | ១ | ១ | ១ | ០ | ៣ |
| | សរុប | ១៦ | ៤៣ | ២៨ | ៥ | ៩២ |
| ហាងសាវ៉ាត | ០ | ១ | ១០ | ៤ | ៤ | ១៩ |
| | ១-៦ | ៨ | ៣០ | ១៥ | ៥ | ៥៨ |
| | ៧-៩ | ០ | ៦ | ៦ | ២ | ១៤ |
| | ១០-១២ | ០ | ៥ | ១ | ៤ | ១០ |
| | សរុប | ៩ | ៥១ | ២៦ | ១៥ | ១០១ |
| កំភុន | ០ | ២ | ២០ | ១៥ | ១២ | ៤៩ |
| | ១-៦ | ៧ | ៧៥ | ៥០ | ៥ | ១៣៧ |
| | ៧-៩ | ១ | ២៥ | ១៥ | ០ | ៤១ |
| | ១០-១២ | ១ | ៨ | ៩ | ២ | ២០ |
| | សរុប | ១១ | ១២៨ | ៨៩ | ១៩ | ២៤៧ |
| ក្រឡាពុះ | ០ | ១ | ១១ | ០ | ២ | ១៤ |
| | ១-៦ | ១ | ៥ | ៩ | ០ | ១៥ |
| | ៧-៩ | ០ | ២ | ១ | ០ | ៣ |
| | ១០-១២ | ០ | ២ | ០ | ០ | ២ |
| | សរុប | ២ | ២០ | ១០ | ២ | ៣៤ |
| ខ្សាច់ថ្មី | ០ | ៩ | ៣៦ | ១៩ | ៥ | ៦៩ |
| | ១-៦ | ៩ | ៤៥ | ៣០ | ១ | ៨៥ |
| | ៧-៩ | ០ | ៤ | ៤ | ០ | ៨ |
| | ១០-១២ | ០ | ៦ | ០ | ១ | ៧ |
| | សរុប | ១៨ | ៩១ | ៥៣ | ៧ | ១៦៩ |
| ភ្លុក | ០ | ២ | ១៥ | ១៩ | ៨ | ៤៤ |
| | ១-៦ | ៤ | ៤៧ | ២៩ | ១ | ៨១ |
| | ៧-៩ | ០ | ១១ | ៤ | ០ | ១៥ |
| | ១០-១២ | ០ | ១ | ១ | ០ | ២ |
| | សរុប | ៦ | ៧៤ | ៥៣ | ៩ | ១៤២ |
| រំពាត់ | ០ | ១ | ៨ | ៧ | ២ | ១៨ |
| | ១-៦ | ១ | ៦ | ៤ | ០ | ១១ |
| | ៧-៩ | ០ | ២ | ០ | ០ | ២ |
| | ១០-១២ | ០ | ២ | ០ | ០ | ២ |
| | សរុប | ២ | ១៨ | ១១ | ២ | ៣៣ |
| សាមឃួយ | ០ | ២ | ៥ | ៧ | ៣ | ១៧ |
| | ១-៦ | ៣ | ២៤ | ២១ | ២ | ៥០ |
| | ៧-៩ | ០ | ៥ | ២ | ១ | ៨ |

| | | | | | | |
|---|---|---|---|---|---|---|
| | ១០-១២ | ១ | ៥ | ៣ | ១ | ១០ |
| | សរុប | ៦ | ៣៩ | ៣៣ | ៧ | ៨៥ |
| សេសាន | ០ | ៣ | ១០ | ១១ | ៩ | ៣៣ |
| | ១-៦ | ៤ | ១៥ | ៦ | ២ | ២៧ |
| | ៧-៩ | ០ | ៣ | ០ | ០ | ៣ |
| | ១០-១២ | ០ | ១ | ០ | ១ | ២ |
| | សរុប | ៧ | ២៩ | ១៧ | ១២ | ៦៥ |
| ស្រែគរ១ | ០ | ៣ | ២៣ | ១៥ | ៤ | ៤៥ |
| | ១-៦ | ១ | ២៧ | ១៨ | ០ | ៤៦ |
| | ៧-៩ | ០ | ៣ | ០ | ១ | ៤ |
| | ១០-១២ | ០ | ១ | ២ | ០ | ៣ |
| | សរុប | ៤ | ៥៤ | ៣៥ | ៥ | ៩៨ |
| ស្រែគរ២ | ០ | ៧ | ២៧ | ១០ | ៨ | ៥២ |
| | ១-៦ | ២ | ២០ | ១៣ | ៣ | ៣៨ |
| | ៧-៩ | ០ | ១ | ២ | ០ | ៣ |
| | ១០-១២ | ០ | ២ | ២ | ០ | ៤ |
| | សរុប | ៩ | ៥០ | ២៧ | ១១ | ៩៧ |
| ស្វាយរៀង | ០ | ៩ | ៥១ | ៣២ | ៩ | ១០១ |
| | ១-៦ | ២ | ៣២ | ១៤ | ២ | ៥០ |
| | ៧-៩ | ០ | ៤ | ២ | ០ | ៦ |
| | ១០-១២ | ០ | ៨ | ០ | ០ | ៨ |
| | សរុប | ១១ | ៩៥ | ៤៨ | ១១ | ១៦៥ |
| តាឡាត | ០ | ២ | ១៤ | ៦ | ២ | ២៤ |
| | ១-៦ | ១ | ៥ | ៦ | ១ | ១៣ |
| | ១០-១២ | ០ | ២ | ០ | ០ | ២ |
| | សរុប | ៣ | ២១ | ១២ | ៣ | ៣៩ |
| សរុបរួម | ០ | ៥០ | ២៧២ | ១៧៧ | ៨៦ | ៥៨៥ |
| | ១-៦ | ៥៦ | ៣៩៥ | ២៥១ | ២៧ | ៧២៩ |
| | ៧-៩ | ៣ | ៨៣ | ៤១ | ៦ | ១៣៣ |
| | ១០-១២ | ៣ | ៤៦ | ២៤ | ១០ | ៨៣ |
| | សរុប | ១១២ | ៧៩៦ | ៤៩៣ | ១២៩ | ១៥៣០ |

### ៣.១.៤ ការប្រកបមុខរបរ

ការប្រកបមុខរបររបស់ប្រជាជននៅក្នុងភូមិនីមួយៗ មានន័យថាជាការប្រើប្រាស់កម្លាំងពលកម្មរបស់ខ្លួន ដើម្បីធ្វើការងារសំរាប់រកប្រាក់ចំណូល ឬដើម្បីចិញ្ចឹមជីវិតនៅក្នុងគ្រួសារ ។ នៅក្នុងគ្រួសារនីមួយៗមានចំនួនសមាជិកខុសៗគ្នា ហើយការប្រើប្រាស់កម្លាំងពលកម្មរបស់ប្រជាជនម្នាក់ៗក៏មានភាពខុសៗគ្នាដែរ ។ ប្រជាជនខ្លះមានមុខរបរតែមួយមុខ ហើយប្រជាជនខ្លះទៀតមានមុខរបរច្រើន ក្នុងនោះមុខរបរមួយចំនួនខុសពេលវេលា និង រដូវកាលគ្នា និង

មុខរបរខ្លះទៀតក្នុងរដូវកាល និង ពេលវេលាជាមួយគ្នា ។ នៅក្នុងតារាងខាងក្រោមបង្ហាញពីចំនួនកម្លាំងពលកម្ម ដែលប្រើប្រាស់សំរាប់ប្រកបមុខរបររបស់ប្រជាជនម្នាក់ៗ តាមភូមិនីមួយៗ។

# តារាង ចំនួនកម្លាំងពលកម្មតាមប្រភេទមុខរបរក្នុងភូមិនីមួយៗ

ចំនួនប្រជាជន តាមប្រភេទមុខរបរចំបងៗ នៅក្នុងភូមិ

| ឈ្មោះភូមិ | ភេទ ១=ប្រុស, ២=ស្រី | ស្រែចំការ | នេសាទ | ចិញ្ចឹមសត្វ | ផល អនុផលព្រៃឈើ | ប៉ូលីស ទាហាន | កម្មករ | លក់ដូរ | រៀន | អាជ្ញាធរភូមិឃុំស្រុក | បិតស្រា | អាចារ្យ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បាដើម | ១ | ១៣០ | ២ | ២៦ | ០ | ៤ | ១១ | ០ | ៦៩ | ៣ | ០ | ០ |
| | ២ | ១២៩ | ១ | ២៤ | ០ | ១ | ៨ | ២ | ៦៥ | ០ | ១ | ០ |
| | សរុប | ២៥៩ | ៣ | ៥០ | ០ | ៥ | ១៩ | ២ | ១៣៤ | ៣ | ១ | ០ |
| បានប៉ុង | ១ | ៧២ | ៣ | ២៣ | ០ | ៣ | ០ | ១ | ៤៨ | ៣ | ០ | ០ |
| | ២ | ៧១ | ២ | ៧ | ០ | ០ | ២ | ០ | ៤៦ | ១ | ១ | ០ |
| | សរុប | ១៤៣ | ៥ | ៣០ | ០ | ៣ | ២ | ១ | ៩៤ | ៤ | ១ | ០ |
| បានម៉ៃ | ១ | ៨៨ | ១ | ១០ | ៥ | ៦ | ៩ | ០ | ៦០ | ៣ | ០ | ០ |
| | ២ | ១០៤ | ០ | ៩ | ០ | ០ | ៧ | ៤ | ៤៦ | ២ | ០ | ០ |
| | សរុប | ១៩២ | ១ | ១៩ | ៥ | ៦ | ១៦ | ៤ | ១០៦ | ៥ | ០ | ០ |
| ហាងសាវ៉ាត | ១ | ១២១ | ០ | ១២ | ០ | ២ | ២ | ០ | ៧៨ | ១ | ០ | ០ |
| | ២ | ១៤៤ | ០ | ៩ | ០ | ០ | ០ | ០ | ៦៦ | ០ | ០ | ០ |
| | សរុប | ២៦៥ | ០ | ២១ | ០ | ២ | ២ | ០ | ១៤៤ | ១ | ០ | ០ |
| កំភុន | ១ | ២១៥ | ១ | ៣៦ | ៤ | ៥១ | ១០ | ៣ | ២២៦ | ១៣ | ០ | ២ |
| | ២ | ២៨០ | ០ | ៣២ | ១ | ១ | ១២ | ១៣ | ២២៧ | ២ | ១ | ០ |
| | សរុប | ៤៩៥ | ១ | ៦៨ | ៥ | ៥២ | ២២ | ១៦ | ៤៥៣ | ១៥ | ១ | ២ |
| ក្រឡាពុះ | ១ | ៤៨ | ០ | ១១ | ១ | ០ | ១ | ០ | ៣៩ | ១ | ០ | ០ |
| | ២ | ៤៧ | ០ | ១ | ០ | ០ | ០ | ០ | ២៦ | ១ | ០ | ០ |
| | សរុប | ៩៥ | ០ | ១២ | ១ | ០ | ១ | ០ | ៦៥ | ២ | ០ | ០ |
| ខ្សាច់ថ្មី | ១ | ២០២ | ០ | ៣៨ | ១ | ៧ | ២ | ២ | ១២៤ | ២ | ០ | ០ |
| | ២ | ២៣១ | ០ | ៥ | ០ | ០ | ០ | ៦ | ១០៧ | ០ | ០ | ០ |
| | សរុប | ៤៣៣ | ០ | ៤៣ | ១ | ៧ | ២ | ៨ | ២៣១ | ២ | ០ | ០ |

| ឈ្មោះភូមិ | ភេទ ១=ប្រុស, ២=ស្រី | ពេទ្យសត្វ | ពេទ្យមនុស្ស | ជាងដែក | ឈ្មួញកណ្តាល | ជាងឈើ ម៉ូតូ កាត់ដេរ | សំអាងការ | ឆ្មបបុរាណ | លោកសង្ឃ | គ្រូបង្រៀន | ម៉ូតូឌុប | អ្នកភ្លេង | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បាដើម | ១ | ០ | ១ | ០ | ០ | ០ | ០ | ០ | ៣ | ១ | ០ | ០ | ២៨២ |
| | ២ | ០ | ០ | ០ | ១ | ០ | ០ | ០ | ១ | ១ | ០ | ០ | ២៦៥ |
